# ប្រាសាទបន្ទាយស្មោង

ប្រាសាទបន្ទាយស្មោង មានទីតាំងស្ថិតនៅភូមិបន្ទាយស្មោង ឃុំបន្ទាយស្មោង ស្រុកស្មោង ខេត្តកំពង់ធំ ដែលមានចម្ងាយប្រមាណ ៥៦ គ.ម. ភាគខាងលិចទីរួមខេត្តកំពង់ធំ និងមានចម្ងាយប្រមាណ ៨ គ.ម. ពីទីប្រជុំជនស្រុកស្មោង។ ឈ្មោះ "បន្ទាយស្មោង" នេះ អ្នកស្រុកហៅសំដៅលើប្រាសាទផង និងសំដៅដល់ឈ្មោះទីតាំងស្ថាននាមជាភូមិនិងឃុំផង។ "បន្ទាយ" មានន័យដើមថា "កំពែង" ពោល គឺសំដៅលើសំណង់ជាដី ឥដ្ឋ ឬថ្ម ដែលព័ទ្ធជុំវិញ ឬខ្លះមានគូទឹកជុំវិញ។ រីឯ "ស្មោង" ទំនងក្លាយមកពីពាក្យបុរាណថា "ចទោង" ហើយត្រូវនឹងពាក្យឬសប្រើដល់សព្វថ្ងៃថា "ទោង" ដែលអាចសំដៅលើរូបរាងដែលកោង បត់បែន ពត់ពែន ដូចគេយោលទោងដូច្នោះដែរ។ ម៉្យោះហើយ ការដែលអ្នកស្រុកហៅប្រាសាទនេះថា "បន្ទាយស្មោង" ទំនងគេសំដៅលើកំពែងប្រាសាទដែលធ្វើអំពីឥដ្ឋមានរាងកោង ឬរាងដូចទឹករលក។ តែសព្វថ្ងៃ កំពែងប្រាសាទដែលធ្វើអំពីឥដ្ឋរបស់ប្រាសាទនេះ បានកប់ក្នុងដីមើលស្ទើរតែលែងយល់ទៅហើយ។

កន្លងមក ប្រាសាទនេះពុំសូវមានអ្នកសិក្សាចាប់អារម្មណ៍ច្រើនឡើយ តែក៏នៅតែមានអ្នកធ្លាប់មកសិក្សាតាំងពីវាងដើមស.វ.ទី២០ ហើយអ្នកស្រាវជ្រាវទាំងនោះមានដូច លោក Lunet De Lajonquière ឆ្នាំ១៩០២ លោក Henri Parmentier ឆ្នាំ១៩១៣ លោក M. Dufosse ឆ្នាំ១៩១៨ លោក Robert Dalet ឆ្នាំ១៩៣៦ ។ល។ ប៉ុន្តែ ការសិក្សាទាំងអម្បាលម៉ាន រៀបរាប់សង្ខេបតិចបំផុត ពោល គឺអាចរាប់បានថាជាបញ្ជីសារពើភណ្ឌតែប៉ុណ្ណោះ។

ប្រាសាទបន្ទាយស្មោង សាងសង់ឡើងអំពីឥដ្ឋ មានរាងបួនជ្រុងស្មើ មានកំពែងឥដ្ឋព័ទ្ធជុំវិញ ហើយបែរមុខទៅទិសខាងកើត ពោល គឺបែរមុខត្ដោះទៅរកស្ទឹងស្មោងដែលនៅក្បែរប្រាសាទតែម្តង (រូបលេខ១-៣)។ ប្រាសាទនេះ នៅសល់រូបរាងច្រើនគួរសម តែគួរឱ្យសោកស្ដាយដែលជញ្ជាំងទាំងមូលនៃប្រាសាទ អ្នកស្រុកបានយកឥដ្ឋចាស់មកបិតបន្ថែមសារជាថ្មី ធ្វើឱ្យយើងមានភាពពិបាកនឹងកំណត់រូបរាងដើមនៃប្រាសាទ (រូបលេខ៤) ហើយក្រៅពីនេះគេបានយកឥដ្ឋចាស់លាយជាមួយឥដ្ឋថ្មី សាងជាសសរនិងពោងលយមកខាងមុខទៀតផង។ រីឯផ្នែកដំបូលវិញ គឺមានរលុះឥដ្ឋធ្លាក់មកក្រោមយ៉ាងច្រើន រួមទាំងធ្លាក់ដំបូលរាងដូចផ្កាឈូកធ្វើអំពីថ្មភក់មកក្រោមផង (រូបលេខ៥)។ នៅក្នុងការសិក្សារបស់លោក Lunet De Lajonquière បានរៀបរាប់ថា នៅច្រកខាងកើតមានផ្តែរទ្វារព្រះឥន្ទ្រគង់លើដំរីក្បាលបី[៧] ប៉ុន្តែសព្វថ្ងៃផ្តែរទ្វារនេះបានបាត់បង់ទៅហើយ និងអ្នកស្រុកជំនួសវិញដោយរូបចម្លាក់ផ្តែរសម័យថ្មីជាព្រះពុទ្ធរូប និងបន្ថែមហោជាងជារូបព្រះពុទ្ធចូលបរិនិព្វាន

[៧] Lajonquière, 1902.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

(រូបលេខ២៦)។ ចំណុចនេះសបញ្ជាក់អំពីការវិវត្តនៃសាសនាក្នុងរបត់ថ្មី លើសំណង់ចាស់ដដែល ពោល គឺការវិវត្តជំនឿពីព្រហ្មញ្ញសាសនាមកជាព្រះពុទ្ធសាសនាថេរវាទ។

ក្រៅអំពីប្រាសាទ យើងអាចឃើញបំណែកវត្ថុសិល្បៈធ្វើអំពីថ្មភក់នៅសម័យបុរាណជាច្រើន ដែលគេយកមកទុកនៅពយ៉ាយមុខប្រាសាទ (រូបលេខ២៧-៨)។ វត្ថុទាំងនេះ ទំនងគេយកមកពីទួលប្រាសាទបុរាណនៅជុំវិញប្រាសាទបន្ទាយស្ទោង ហើយយកមកទុកនៅទីនេះយូរមកហើយ។ ពោល គឺមានលក្ខណៈដូចនៅប្រាសាទព្រះធាតុរកាក្នុងសង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ឯណោះដែរ ដែលមានន័យថា អ្នកស្រុកនៅតែគិតថា វត្ថុទាំងអស់ដែលជារបស់បុរាណសុទ្ធសឹងតែមានវិញ្ញាណនិងជារបស់ដែលជាទីគោរពប្រណិប័តន៍យ៉ាងខ្ជាប់ខ្ជួន។ វត្ថុសិល្បៈទាំងនេះ មានខ្លះជាវត្ថុសិល្បៈសម័យមុនអង្គរ ជាក់ស្តែងដូចជា បំណែកសសរពេជ្រជាដើម ហើយក្រៅពីនេះមានជើងទម្រ កំពូលប្រាសាទ បំណែកចម្រឹងបង្អួច បំណែកព្រះពុទ្ធប្រក់នាគ បំណែកបដិមា។ល។ ជាវត្ថុសិល្បៈនៅសម័យអង្គរចាប់ពីស.វ.ទី១០ ដល់ស.វ.ទី១៣។

អ្វីគួរកត់សម្គាល់បន្ថែម នៅមិនឆ្ងាយប៉ុន្មានពីប្រាសាទបន្ទាយស្ទោង មានស្ថានីយបុរាណជាច្រើនដែលសុទ្ធសឹងជាទីតាំងប្រាសាទបុរាណដែលបាក់បែកក្លាយជាទួល ក្នុងនោះមានដូចជា ទួលយាយទែត ទួលវត្តចាស់ ទួលអ្នកតាពុទ្ធិវង្ស ទួលប្រាសាទដូនប៉េង។ល។ ហេតុដូច្នេះហើយ សំណង់បុរាណនៅបន្ទាយស្ទោង និងទីតាំងបុរាណដែលរៀបរាប់នេះ ប្រាកដជាមានទំនាក់ទំនងនឹងគ្នាជាក់មិនខាន ហើយអាចឱ្យយើងសន្និដ្ឋានបានថា ទីតាំងនៅម្តុំប្រាសាទបន្ទាយស្ទោង គឺជាទីប្រជុំជនមួយដ៏សំខាន់តាំងពីសម័យអង្គរមកម្ល៉េះ។

ដោយហេតុថា ប្រាសាទបន្ទាយស្ទោង មិនមានសេសសល់នូវសិលាចារឹក និងគ្រឿងលម្អជាប់នឹងប្រាសាទដែលអាចឱ្យយើងកត់សម្គាល់ជាធំដុំនោះ យើងមានការពិបាកក្នុងការកំណត់អាយុកាលរបស់ប្រាសាទ។ ប៉ុន្តែ បើយើងក្រឡេកមើលផ្នែកស្ថាបត្យកម្ម និងបំណែកវត្ថុសិល្បៈដែលនៅពយ៉ាយខាងមុខប្រាសាទ យើងអាចទាញសេចក្តីសន្និដ្ឋានបឋមបានថា បន្ទាយស្ទោងទំនងជាប្រាសាទកសាងឡើងដើម្បីឧទ្ទិសដល់ព្រហ្មញ្ញសាសនា ឬព្រះពុទ្ធសាសនា នៅសម័យអង្គរ ក្នុងរវាងស.វ.ទី១០ ពោល គឺអាចចន្លោះពីរជ្ជកាលព្រះហស៌វរ្ម័នទី១ (គ.ស.៩១០-៩២២) ដល់រជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ (គ.ស.៩៦៨ - ១០០០)។ សំណង់ប្រាសាទបន្ទាយស្ទោងទៀតសោត គឺជាស្ថាបត្យកម្មសាសនាមួយក្នុងចំណោមសំណង់ប្រាសាទជាច្រើន ដែលបានតាំងទីនៅតាមបណ្តោយស្ទឹងស្ទោង ជាក់ស្តែង ប្រាសាទអំបែងធំ ប្រាសាទត្រពាំងព្រីង ប្រាសាទតាឡោក ប្រាសាទវត្តព្រះដំរី ប្រាសាទវត្តក្តីដើម ។ល។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# ឯកសារយោង

**Lunet De Lajonquière**
1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris.



រូបលេខ១៖ ប្រាសាទបន្ទាយស្ទោង មើលពីទិសខាងកើត

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៖ ប្រាសាទបន្ទាយស្នោង មើលពីទិសពាយព្យ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ៣៖ ប្រាសាទបន្ទាយស្មោង មើលពីទិសនិរតី*

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*



រូបលេខ៤៖ លម្អិតជញ្ជាំងប្រាសាទបន្ទាយស្មោងដែលអ្នកស្រុករៀបឥដ្ឋសារជាថ្មី

អត្ថបទដោយ៖ ម៉ង់ រ៉ាលី




រូបលេខ៦៖ ការជំនួសផ្តែរទ្វារចាស់មានរូបព្រះឥន្ទ្រជិះដំរី ផ្លាស់ថ្មីជាព្រះពុទ្ធរូប និងបន្ថែមហោជាងរូបព្រះពុទ្ធរូបចូលបរិនិព្វាននៅប្រាសាទបន្ទាយស្មោង

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៦៖ ថ្មក្បាច់កំពូលប្រាសាទដែលធ្លាក់មកក្រោមនៅប្រាសាទបន្ទាយស្មោង



រូបលេខ៧៖ វត្ថុសិល្បៈសម័យអង្គរ រក្សាទុកនៅមុខប្រាសាទបន្ទាយស្មោង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៨៖ បំណែកសសរពេជ្រសម័យមុនអង្គរ រក្សាទុកនៅមុខប្រាសាទបន្ទាយស្ទោង

អត្ថបទដោយ៖ ម៉ង់ រ៉ាលី